# សុន្ទរកថា
# តំណាងសង្គមស៊ីវិល ដែលថ្លែងក្នុងពិធី
# ប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍
# ០១ធ្នូ ២០១៣

- សូមគោរព **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន** ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង ជាតំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
- សូមគោរព **ឯកឧត្តម អៀង មូលី** ទេសរដ្ឋមន្ត្រី និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងទូត ដៃគូអភិវឌ្ឍន៍ និង តំណាងអង្គការជាតិ និង អន្តរជាតិជាទីគោរព ។
- បងប្អូនអ្នកផ្ទុកមេរោគអេដស៍ ដែលមានវត្តមាននៅទីនេះជាទីស្រលាញ់រាប់អាន!

ក្នុងនាមសង្គមស៊ីវិល ដែលកំពុងអនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សក្រៃលែង ដែលបានចូលរួមជាកិត្តិយស ក្នុងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមប្រធានបទ "**ឈានឆ្ពោះទៅរក គ្មានការឆ្លងថ្មី គ្មានការរើសអើង គ្មានការស្លាប់**" ។

ឆ្លៀតនៅក្នុងឱកាសនេះ យើងខ្ញុំសូមសម្តែងនូវមោទនភាពដល់គ្រប់ស្ថាប័នទាំងអស់ ជាពិសេស ដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបង្កឲ្យមានការចូលរួម ជាពហុវិស័យ ពីគ្រប់ ស្ថាប័នទាំងអស់ និងអង្គការសង្គមស៊ីវិល ។ ក្នុងកិច្ចការងារនេះ ជាមួយរដ្ឋាភិបាល រហូតទទួលបានជោគជ័យជាបន្តបន្ទាប់ និង ទទួលស្គាល់ជាលក្ខណៈជាតិ និង អន្តរជាតិ នូវអត្រានៃការផ្ទុកមេរោគអេដស៍ចុះមកត្រឹម0.៧%នៅឆ្នាំ២០១២ ។ យើងសូមអបអរសាទរនូវការជោគជ័យនេះ ដែលជាមោទនភាពជាតិ !

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព!

នាពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជា ក៏ដូចជាប្រទេសនានានៅក្នុងតំបន់ នៅទូទាំងពិភពលោក បាននឹងកំពុងសហការរួមគ្នា ក្នុងការសំរេចឲ្យបាន នូវគោលដៅរួមមួយ ដែលឆ្ពោះឈានទៅរកភាពសូន្យ គឺគ្មានការចម្លងថ្មី គ្មានការរើសអើង និង គ្មានការស្លាប់ ។ នៅពេលដែលបានលឺ និង ឃើញនូវគោលដៅរួមនេះ យើងមានការអបអរណាស់ ដោយរំពឹងថា នឹងនៅឆ្នាំ២០១៥

និង ២០២០ យើងនឹងឃើញនូវលទ្ធផលទាំងនោះ ប៉ុន្តែយើងនៅមានការបារម្ភណ៍ថាតើយើងសំរេចគោលដៅទាំងនោះបានដែរឬទេ ? ។

ដើម្បីចូលរួមចំនែក ក្នុងការសំរេចឲ្យបានជោគជ័យ នូវគោលដៅដែលបានគ្រោងទុកនេះ តាងនាមឲ្យអង្គការសង្គមស៊ីវិល យើងសូមលើកយកនូវចំនុចមួយចំនួន មានដូចខាងក្រោម៖

**កម្មវិធីបង្ការ**

ក្រុមប្រឈមមុខខ្ពស់ មានដូចជាក្រុមបុរសស្រលាញ់បុរស អ្នកបំរើសេវាកំសាន្ត ក្រុមក្រុមអ្នកប្រើប្រាស់ និង បំពានគ្រឿងញៀន យុវវ័យ និង ក្រុមចល័តគឺជាក្រុមដែលគេចាត់ទុកថាជាក្រុម ដែលប្រឈមមុខខ្ពស់ក្នុងការឆ្លងមេរោគអេដស៍ ។ តែបើយើងពិនិត្យមើល ឃើញថាអត្រាគ្របដណ្តប់ នៃបទអន្តរាគមន៍ចំពោះក្រុមប្រឈមទាំងនេះ ដូចជានៅមានកម្រិតទាបនៅឡើយ បើតាមរបាយការណ៍នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង អត្រាចម្លងមេរោគអដស៍ពីម្តាយទៅកូន គឺនៅមានខ្ពស់នៅឡើយ ប្រមាណជា១១% នៅឆ្នាំ២០១០នេះ បើតាមរបាយការណ៍ពីការពិនិត្យឡើងវិញទៅលើវិស័យសុខាភិបាល ដែលរៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអដស៍ សើស្បែក និងកាមរោគ និងស្ត្រីដែលមានផ្ទៃពោះ ដែលមិនបានទៅទទួលសេវាកាត់បន្ថយការឆ្លងមេរោគអេដស៍ទៅកូន ក៏នៅមានកំរិត ។ យុវជនជាច្រើននៅខ្វះចំណេះដឹង ទាក់ទង់នឹងសុខភាពបន្តពូជ ដែលជាហេតុនាំឱ្យពួកគេមានផ្ទៃពោះដោយចៃដន្យ ការឆ្លងនូវកាមរោគ មេរោគអេដស៍ និង អត្រាប្រើប្រាស់ស្រោមអនាម័យនៅទាបក្នុងចំណោមដៃគូសង្សារបស់ស្ត្រីធ្វើការនៅតាមតំបន់កំសាន្ត ។ ជាងនេះទៅទៀតនោះ ក្រុមប្រឈមមុខក្នុងការឆ្លងមេរោគអេដស៍ នៅមិនទាន់មានការកែប្រែឥរិយាបថក្នុងការរួមភេទប្រកដដោយសុវត្ថិភាព និង ការមកទទួលសេវាសុខភាព ក៏នៅមានកំរិត ជាពិសេស ការមកធ្វើតេស្តឈាមរកមេរោគអេដស៍នៅមណ្ឌលសុខភាព។

**ការមាក់ងាយរើសអើង**

បើតាមការសិក្សាពីការមាក់ងាយ និង ការរើសអើងពីមេរោគអេដស៍ ដែលរៀបចំដោយបណ្តាញនៃអ្នកផ្ទុកមេរោគអដសំ និង ជំងឺអដសំ ក្នុងប្រទេសកម្ពុជា បានបង្ហាញអោយឃើញថាការរើសអើងពីសំណាក់អ្នកផ្តល់សេវា ពីសំណាក់សហាគមន៍ អ្នកជំងឺអេដស៍មានការរើសអើងដោយខ្លួនឯង គឺនៅតែមាន។ អ្នកជំងឺអេដស៍ខ្លះទៀតធ្លាប់ត្រូវបានគេរំលោភបំពានសិទ្ធិ និង ត្រូវបានគេបដិសេធមិនលក់សេវាធានារ៉ាប់រងសុខភាព និង ផ្តល់ប្រាក់កំចី ។ ក្រុមងាយរងគ្រោះរួមមានក្រុមបុរសស្រឡាញ់បុរស ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន និង ក្រុមអ្នកធ្វើការនៅតំបន់សេវាកម្សាន្តសប្បាយ ទទួលរងនូវការរើសអើងពីសហាគមន៍ កន្លែងបម្រើការងារ និងអតិថិជន ។ ជាងនេះទៅទៀតនោះ អ្នកផ្ទុកមេរោគអេដស៍ និង ក្រុមប្រឈមមុខខ្ពស់នៅមានការ

រើសអើងដោយខ្លួនឯង ដោយមានការភ័យខ្លាច និងការចេញមកទទួលសេវាសុខភាពជាសាធារណៈផងដែរ។

**កម្មវិធីថែទាំ គាំទ្រ និងព្យាបាល**

កម្មវិធីព្យាបាល និងថែទាំអ្នករស់នៅជាមួយមេរោគអេដស៍ មានការកើនឡើង និង អត្រាគ្របដណ្តប់ នៃការផ្តល់ឱសថប្រឆាំងមេរោគអេដស៍ មានរហូតជាង៨០% ដែលផ្តល់ឲ្យឥតគិតថ្លៃ ។ ទោះបីជាមានការជោគជ័យយ៉ាងណា ក៏នៅឃើញថា ឱសថទាំងនោះមានការខ្វះខាត ជាពិសេសឱសថព្យាបាលជំងឺឱកាសនិយម និងប្រតិករពិនិត្យគ្រប់ឈាមមើលមេរោគអេដស៍ផងដែរ នេះបើផ្អែកតាមការលើកឡើងក្នុងកិច្ចប្រជុំប្រចាំតំបន់ ដែលរៀបចំដោយគណៈកម្មាធិការសំរបសំរួលប្រយុទ្ធនឹងជំងឺអដស៍។ ជាងនេះទៅទៀតនោះ ការងារថែទាំ គាំទ្រដល់អ្នករស់នៅជាមួយមេរោគអេដស៍ ជាការងារដ៏សកម្មមួយរបស់អង្គការសង្គមស៊ីវិល តែការងារទាំងនេះត្រូវបានកាត់បន្ថយមកវិញជាបន្តបន្តប់បន្ទាប់ ពីអង្គការជាច្រើនមានការខ្វះខាតថវិកាក្នុងការអនុវត្តកម្មវិធីថែទាំទាំងនេះ។

ជាងនេះទៅទៀតនោះ យើងក៏ត្រូវពិនិត្យមើលវិញផងដែរ នូវការបង្កើតច្បាប់ និង គោលនយោបាយ ដើម្បីធានាថាច្បាប់ និង គោលនយោបាយទាំងនោះ មិនជាឧបសគ្គរាំងទៅដល់ការអនុវត្តន៍ការអប់រំបង្ការ និងការថែទាំព្យាបាលទៅដល់អ្នកដែលកំពុងត្រូវការសេវាទាំងនោះ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីគោរព!

ដើម្បីធានាពីនិរន្តរភាព សង្គមស៊ីវិលស្នើសុំទៅរាជរដ្ឋាភិបាល មេត្តាបង្កើននូវការប្តេជ្ញាចិត្តនិង ការចូលរួមឲ្យបានខ្លាំងក្លាបន្ថែមទៀត ជាពិសេស ការចូលរួមវិភាគទាន ផ្នែកថវិការបស់ រដ្ឋាភិបាលឲ្យបាន២០%សំរាប់ការងារអេដស៍ និង ជំរុញធ្វើយ៉ាងណា ឲ្យការងារប្រយុទ្ធនឹងជំងឺអេដស៍ រួមទាំងថវិការបស់រាជរដ្ឋាភិបាល ត្រូវបានដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ភូមិសង្កាត់។

ឈ្លាតនៅក្នុងឱកាសនេះ យើងខ្ញុំសូមជំរាបជូនផងដែរថា បន្ទាប់ពីអត្រាផ្ទុកមេរោគអេដស៍នៅប្រទេសកម្ពុជាមានការធ្លាក់ចុះ ដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយដ៏ច្រើនទៀតមានការកាត់បន្ថយថវិកា ឬថយថវិកាទាំងស្រុងតែម្តង ក្នុងការងារអេដស៍ ដែលជាហេតុធ្វើអោយការងារប្រយុទ្ធនឹងមេរោគអេដស៍ និង ជំងឺអេដស៍ មានការធ្លាក់ចុះផងដែរ។ សង្គមស៊ីវិលមានការព្រួយបារម្មណ៍ជាខ្លាំងថា អត្រាផ្ទុកមេរោគអេដស៍អាចនឹងមានការផ្ទុះការរីករាលដាលឡើងវិញ ប្រសិនបើឥរិយាបថរបស់ជនប្រឈមមុខខ្ពស់មិនមានកែប្រែ និង ថវិកាមិនមានគ្រប់គ្រាន់ សំរាប់អនុវត្តកម្មវិធីទាំងនោះ ។

គណៈកម្មាធិការសំរបសំរួលប្រយុទ្ធនឹងជំងឺអេដស៍សិ នឹងបន្តការសហការជាមួយរាជរដ្ឋាភិបាល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការសំរបសំរួលជាមួយនឹងអង្គការសង្គមស៊ីវិល ធ្វើយ៉ាងណាដើម្បីគៀងគរប្រភពធនធានពីប្រភពផ្សេងៗ បន្តជួយនូវការពង្រឹងយន្តការដែលមានស្រាប់ និងជួយផ្តល់ជាការចែករំលែកពត័មានជាយុទ្ធសាស្រ្តនានា ដើម្បីធានាថា ការអនុវត្តសកម្មភាព គឺស្របទៅនឹងផែនការថ្នាក់ជាតិអ្វីដែលជាតំរូវការជាក់ស្តែង នៅតាមសហគម និងការប្រើប្រាស់ថវិកាឲ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងការចូលរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាល ដើម្បីកាត់បន្ថយការរីករាលដាល នៃមេរោគអេដស៍ និង ផលប៉ះពាល់របស់វា នៅក្នុងប្រទេសកម្ពុជា។

ទីបញ្ចប់ យើងខ្ញុំសូមគោរពជូនពរ ឯកឧត្តមឧបនាយករដ្ឋមន្រ្តី ឯកឧត្តម លោកជំទាវ លោក លោកស្រី ទាំងអស់ជួបប្រទះ នឹងពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!